00660452

E9/7/1/1/1/2

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជតក

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១១

**ឯកសារទទួល**
**DOCUMENT RECEIVED/DOCUMENT REÇU**
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 22 / 03 / 2011
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងការជូនដំណឹងចំនួនពីររបស់ អៀង សារី អំពីការប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រសម្រាប់ដាក់អញ្ញត្រកម្ម**

---

**ដាក់ដោយ៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល**

ឯកឧត្តម គង់ ស្រីម

ចៅក្រម Mottoo NOGUCHI

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម Chandra NIHAL JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម យ៉ា ណារិន

ចៅក្រមបំរុង ម៉ុង មុន្នីចរិយា

ចៅក្រមបំរុង Florence MUMBA

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសុំឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជូនដំណឹងចំនួនពីររបស់លោក អៀង សារី អំពីការប្តឹងសាទុក្ខ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានបដិសេធការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់សម្រាប់ដាក់អញ្ញត្រកម្ម (“ចម្លើយតប”)[1] ។ ចម្លើយតបនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះចម្លើយតបមិនអាចទទួលយកបាន ដោយសារវាមានកំហុសផ្នែកច្បាប់ ហើយវាស្វែងរកដំណោះស្រាយដែលមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬ ច្បាប់កម្ពុជាដែលនៅធរមាន ។

## I ការឆ្លើយតប

១. ចម្លើយតបមិនអាចទទួលយកបានទេ ។ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អវតក (“សេចក្តីណែនាំអនុវត្ត”) អនុញ្ញាតឱ្យការឆ្លើយតបទៅនឹងសំណើ និង សារណា[2] មិនមែនឆ្លើយទៅនឹងការជូនដំណឹងនោះទេ ។ បន្ថែមពីលើនេះ ចម្លើយតបមិនបានដាក់នៅក្នុងពេលវេលាកំណត់ដែលអនុញ្ញាតសម្រាប់ការឆ្លើយតប ។ ចម្លើយតបយោងចំពោះការជូនដំណឹងចំនួនពីរដែលដាក់ដោយមេធាវីការពារក្តី ។ ការជូនដំណឹងអំពីការប្តឹងសារទុក្ខលើកទីមួយរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យាពេលកំណត់ (E9/7) និង (E9/4/9) ដែលបានដាក់នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១១[3] ហើយត្រូវបានជូនដំណឹងនៅថ្ងៃទី ៤ មីនា ២០១១។ ប្រសិនបើការជូនដំណឹងនេះអាចត្រូវបានពិចារណាថាជាសារណាមួយ ដែលការឆ្លើយតបមួយត្រូវបានអនុញ្ញាត

[1] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អជតក, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខចំនួនពីរ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធការបន្ថែមពេលវេលា និង បង្កើនចំនួនទំព័រកំណត់សម្រាប់ដាក់អញ្ញត្រកម្ម ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១ E9/7/1/1/1/1, ERN: 00655029-00655033 ។

[2] សូមមើលសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អវតក, សេចក្តីណែនាំអនុវត្ត អវតក/២០០៧/វិសោធនកម្មលើកទី៦ នៅមាត្រា ៨.៣ ។

[3] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អជសជ, ការជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យាពេលកំណត់ (E9/7) និង (E9/4/9 ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១១ E9/7/1/1, ERN: 00649214-00649215 ។

នោះការឆ្លើយតបនេះត្រូវតែបានដាក់នៅក្នុងរយៈពេល ១០ ថ្ងៃ នៃថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃជូនដំណឹង ។ ការឆ្លើយតបត្រូវបានដាក់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១ ដែលមានរយៈពេល ១៤ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីការដាក់ឯកសារនៃការជូនដំណឹងពីការប្ដឹងសាទុក្ខ។ កសព មិនបានផ្ដល់មូលហេតុថាហេតុអ្វីបានជាការដាក់ឯកសារនេះយឺត ដូចដែលតម្រូវដោយមាត្រា ៩ នៃសេចក្ដីណែនាំអនុវត្តនោះ ។

២. ការឆ្លើយតបនេះធ្វើឱ្យមានការភាន់ច្រឡំនៅក្នុងការពិចារណាថាវិធាន ១០៤ គឺជាវិធានតែមួយគត់ដែលផ្ដល់អំណាចដល់អង្គជំនុំជម្រះតុលាការកំពូលដើម្បីសម្រេចលើបណ្ដឹងសាទុក្ខនេះ[4]។ បណ្ដឹងសាទុក្ខទាំងពីរនេះ ដែលការជូនដំណឹងអំពីការប្ដឹងសាទុក្ខគឺអាចទទួលយកបាន អនុលោមតាមវិធាន ២១ ។ វិធាន ២១(១) ចែងថា "ច្បាប់ស្ដីពីការបង្កើត អវតក វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយ ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់ អវតក ដូចមានចែងនៅក្នុងច្បាប់ស្ដីពីការបង្កើត អវតក និងកិច្ចព្រមព្រៀង" [5]។ អាស្រ័យហេតុនេះ វិធាន ២១ តម្រូវឱ្យអង្គជំនុំជម្រះការពារជានិច្ចដល់ផលប្រយោជន៍របស់លោក អៀង សារី ។ អង្គបុរេជំនុំជម្រះកាលពីលើកមុនបានសម្រេចថាវិធាន ២១ តម្រូវឱ្យអង្គបុរេជំនុំជម្រះយល់ឃើញថាបណ្ដឹងឧទ្ធរណ៍អាចទទួលយកបាន ដើម្បីធានាថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានការពារ នៅក្នុងករណីពុំមានវិធានផ្ទៃក្នុងផ្ដល់សិទ្ធិផ្ដល់ដើម្បីប្ដឹងឧទ្ធរណ៍[6] ។ មេធាវីការពារក្ដីស្នើសុំឱ្យពិចារណាថា អង្គជំនុំជម្រះតុលាការកំពូលត្រូវតែអនុវត្តតាមយុត្តិសាស្ត្រនេះ ដែលបង្កើតដោយអង្គបុរេជំនុំជម្រះដើម្បីធានាថាសិទ្ធិជាមូលដ្ឋានរបស់ អៀង សារី ក្នុងការទទួលបានការជំនុំ

[4] ចម្លើយតប នៅកថាខណ្ឌទី២-៣ ។

[5] បញ្ជាក់បន្ថែម ។

[6] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៧១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់ អៀង សារី ទៅនឹងសេចក្ដីសន្និដ្ឋានស្ថាពរតាមវិធាន ៦៦ និងការសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា និងសំណើសុំបង្អង់កិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ នៅកថាខណ្ឌទី១៣ D390/1/2/4, ERN: 00601705-00601717 ។

ជម្រះដោយយុត្តិធម៌ ត្រូវបានការពារ ។

៣. ចម្លើយតបនេះបានធ្វើឲ្យមានការភាន់ច្រឡំបន្ថែមទៀត ចំពោះការខកខានមិនបានទទួលស្គាល់ថា បណ្ដឹងសាទុក្ខនេះអាចទទួលយកបានសមស្របតាមវិធាន ១០៤ ។ វិធាន ១០៤(១) ចែងក្នុងផ្នែកពាក់ព័ន្ធថា "បណ្ដឹងសារទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃការភាន់ច្រឡំ ដែលស្ដែងចេញពីប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ"[7] ។ ដូចដែលបានពន្យល់នៅក្នុងបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូងភាន់ច្រឡំនៅក្នុងការអនុវត្តឆន្ទានុសិទ្ធរបស់ខ្លួន ហើយបណ្ដាលឲ្យប៉ះពាល់ដល់លោក អៀង សារី ។ កសព ថ្លែងដោយភាន់ច្រឡំថា បណ្ដឹងសាទុក្ខភ្លាមៗត្រូវបានដាក់កម្រិតដោយវិធាន ១០៤(២)[8] ។ វិធាន ១០៤(២) គ្រាន់តែចែងថា "អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចតម្កល់ ឬ ទុកជាមោឃៈ ឬកែប្រែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មួយផ្នែក ឬ ទាំងស្រុង ដូចមានចែងនៅក្នុងវិធាន ១១០"។ បណ្ដឹងសារទុក្ខភ្លាមៗមានចែងនៅក្នុងវិធាន ១០៤(៤) ។ បណ្ដឹងសាទុក្ខនេះបំពេញលក្ខខណ្ឌជាបណ្ដឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤)(ក) និង(ឃ) សម្រាប់មូលហេតុនានាដែលបានពន្យល់លំអិតនៅក្នុងបណ្ដឹងសាទុក្ខមែនទែននោះ ។

៤. ចម្លើយតបមិនអាចទទួលយកបានទេ ហើយគ្មានមូលដ្ឋានសំអាងអ្វីសោះ។ កសព អះអាងថា ភាពអាចទទួលយកបានរបស់បណ្ដឹងសាទុក្ខ ត្រូវតែបានដោះស្រាយនៅមុនបណ្ដឹងសាទុក្ខនេះត្រូវបានដាក់យ៉ាងពិតប្រាកដ ហើយអំណះអំណាងរបស់បណ្ដឹងទាំងនេះទាក់ទងនឹងភាពអាចទទួលយកបាន អាចត្រូវបានវិភាគ[9] ។ កសព អះអាងថាការធ្វើដូច្នេះគឺចាំបាច់ ពីព្រោះអង្គជំនុំជម្រះតុលាការកំពូលចាំបាច់ត្រូវ "មានលទ្ធភាពពិនិត្យមើលអង្គសេចក្ដីជាបឋម នៃបណ្ដឹងសាទុក្ខដោយធ្វើការវិភាគខ្លឹមសារនៃការជូនដំណឹងអំពីការប្ដឹងសាទុក្ខ ដោយមិនចាំបាច់ពិចារណាលើ

---

[7] បញ្ជាក់បន្ថែម ។

[8] ចម្លើយតប កថាខណ្ឌទី២ ។

[9] ដូចខាងលើ នៅកថាខណ្ឌទី៦ ។

សារណាបណ្តឹងសារទុក្ខទាំងមូលឡើយ"[10] ។ កសព អះអាងថាប្រសិនបើភាពអាចទទួលយកបាន មិនត្រូវបានសម្រេចនៅពេលនេះ "នោះទម្លាប់នៃការដាក់សារណា ដែលនាំអោយខូចប្រយោជន៍ ដែលត្រូវចំណាយនូវធនធាន និង ពេលវេលារបស់អង្គជំនុំជម្រះ ភាគី និងអង្គភាពបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ ("ITU") ដោយឥតប្រយោជន៍"[11] ។ កសព ខកខានមិនបានទទួលស្គាល់ថា ចម្លើយតបរបស់ខ្លួនគឺជាការខ្ជះខ្ជាយដែលមិនចាំបាច់ដល់ធនធានរបស់អង្គជំនុំជម្រះតុលាការកំពូល ភាគី និងរបស់អង្គភាព ITU ។ អង្គជំនុំជម្រះតុលាការកំពូលពិតជាមានសមត្ថភាពពេញលេញ ក្នុង ការសម្រេចពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ នៅពេលដែលខ្លួនបានទទួលបណ្តឹងសាទុក្ខ ទាំងនេះ និងពិចារណាពីទឡ្ហីករណ៍ទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខទាំងនេះ ។ ពិតណាស់ ប្រសិនបើអង្គជំនុំជម្រះតុលាកំពូលយល់ឃើញថាបណ្តឹងសាទុក្ខទាំងនេះមិនអាចទទួល យកបានទេ នោះខ្លួនមិនបាច់ពិចារណាពីមូលហេតុត្រឹមត្រូវរបស់បណ្តឹងសារទុក្ខទាំងនេះឡើយ។ វាមិនមានការខ្ជះខ្ជាយធនធាន ដែលបណ្តាលមកពីការអនុញ្ញាតឲ្យមានការដាក់បណ្តឹងសាទុក្ខ ទាំងនះឡើយ។

៥. កសព បានលើកឡើងអំពីក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធី ព្រហ្មទណ្ឌ") ដើម្បីគាំទ្រការអះអាង របស់ខ្លួនដែលថា បណ្តឹងសាទុក្ខទាំងនេះគួរតែបដិសេធចោល ថាមិនអាចទទួលយកបានសូម្បីតែនៅមុនពេល ដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួល បណ្តឹងសាទុក្ខទាំងនេះ[12]។ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនតម្រូវឲ្យមានករណីបែបនេះទេ។ ម្យ៉ាងវិញ ទៀត មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានដកស្រង់យកមកសំអាងដោយ កសព នេះ ក៏មិនបានផ្តល់ការគាំទ្រអ្វីដែរ។ មាត្រានេះចែងថា៖

> តុលាការអាចប្រកាសថាមិនអាចទទួលយកនូវបញ្ហាបន្ទាន់បង្ហិតែតាមសាលក្រមដែលមាន សំអាងហេតុតែប៉ុណ្ណោះ ។ កាលណាអញ្ញត្រកម្មមិនបានទទួលការយល់ព្រមទេការ ពិភាក្សាដេញដោលត្រូវបន្ត ។ កាលណាបញ្ហាបន្ទាន់បង្ហិត្រូវបានលើកឡើង និងត្រូវបាន

---

[10] ដូចខាងលើ ។

[11] ដូចខាងលើ ។

[12] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៨ ដល់ ៩។

ទទួលយល់ព្រមដោយតុលាការនោះ តុលាការនេះត្រូវបង្អង់មិនទាន់សម្រេច ហើយកំណត់រយៈពេលកំណត់ឱ្យភាគីពាក់ព័ន្ធប្តឹងទៅតុលាការមានសមត្ថកិច្ច។

៦. មាត្រា ៣៤៥ គ្រាន់តែនិយាយយោងទៅលើនីតិវិធីដែលនឹងត្រូវអនុវត្តតាមក្នុងករណីដែលបណ្តឹងសាទុក្ខបន្ទាន់បន្ទំ ត្រូវបានទទួលយក ឬបដិសេធចោល។ វាមិនបានអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូល បដិសេធមិនទទួលយកការដាក់បណ្តឹងសាទុក្ខតាមជំនឿមួយដែលបង្កើតឡើងដោយមិនបានអានបណ្តឹងសាទុក្ខនេះដែលថា បណ្តឹងសាទុក្ខនេះទំនងជាមិនអាចទទួលយកបាន។ តាមការពិត លក្ខខណ្ឌដែលថាបណ្តឹងសាទុក្ខបន្ទាន់បន្ទំ អាចត្រូវបានគេបដិសេធមិនទទួលយក "តែតាមរយៈសាលក្រមដែលមានសំអាងហេតុ" បានគាំទ្រដល់ការសន្និដ្ឋាននេះ៖ អង្គជំនុំជម្រះតុលាការកំពូលត្រូវតែអនុញ្ញាតឱ្យគេដាក់បណ្តឹងសាទុក្ខ ហើយត្រូវពិចារណាអំពីទឡ្ហីករណ៍ទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខទាំងនេះ ដើម្បីឱ្យខ្លួនអាចចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុ។ ការនិយាយយោងរបស់ កសព ទៅលើយុត្តិសាស្ត្រនៅតុលាការ ICTY គឺមិនពាក់ព័ន្ធគ្នាឡើយ ព្រោះនីតិវិធីទាក់ទងនឹងបណ្តឹងសាទុក្ខនៅតុលាការ ICTY គឺខុសគ្នានឹងនីតិវិធីនៅ អវតក។ កសព មិនបានប្រឹងប្រែងដើម្បីបញ្ជាក់ថាភាពខុសគ្នាត្រូវបានសម្របសម្រួលយ៉ាងដូចម្តេច ហើយបង្ហាញថាហេតុអ្វីបានជានីតិវិធីនៅតុលាការ ICTY គួរត្រូវយកមកប្រើប្រាស់ដើម្បីជំនួស ឬ ដើម្បីគេចវេសនីតិវិធីរបស់ អវតក។

៧. នៅទីបញ្ចប់ កសព បានលើកឡើងដោយប្រយោលថា បណ្តឹងសាទុក្ខទាំងនេះ "គ្មានមូលដ្ឋានជាក់ស្តែងច្បាស់ក្រឡែត[13] ហើយមិនបានគោរពដល់វិធានផ្ទៃក្នុង ឬសេចក្តីណែនាំអនុវត្តនៅ អវតក ឡើយ[14]"។ កសព បានលើកឡើងថា "ចៅក្រមនៅ អវតក មានកាតព្វកិច្ចធានាថាធនធាន និងពេលវេលាដ៏មានតម្លៃ មិនត្រូវបានគេយកមកចំណាយលើសារណាដែលមិនមានមូលដ្ឋានជាក់ស្តែងច្បាស់ក្រឡែត ដែលអាចបង្អាក់ពួកគេពីការអនុវត្តកាតព្វកិច្ចសំខាន់ក្នុងការធានាឱ្យមានការជំនុំជម្រះក្តីមួយឱ្យបានឆាប់រហ័ស និងយុត្តិធម៌នោះទេ[15]"។ ជាថ្មីម្តងទៀត ចម្លើយតបនេះទៅ

---

[13] ចម្លើយតប, កថាខណ្ឌទី១១។

[14] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១២។

[15] ដូចជើងទំព័រខាងលើ។

វិញទេ ដែលធ្វើឱ្យខូះខ្នាយដល់ធនធានតុលាការ មិនមែនជាបណ្ដឹងសាទុក្ខទេ ។ ឥឡើយតបនេះគឺ មិនអាចទទួលយកបានទេ ហើយមិនចាំបាច់ត្រូវយកទៅពិចារណាឡើយ ។ ម្យ៉ាងវិញទៀត គឺ កសព ដែលហាក់បីដូចជាមិនគោរពតាមនីតិវិធីជាធរមាន មិនមែនជាមេធាវីការពារក្ដីទេ ។ វាមិន បានចែងក្នុងសេចក្ដីណែនាំអនុវត្ត អំពីការធ្វើចម្លើយតបនឹងការជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ឡើយ[16]។ ចម្លើយតបមិនអាចទទួលយកបាន ហើយមិនចាំបាច់ពិចារណាឡើយ។

៨. ប្រសិនបើ កសព ចង់បានការពិភាក្សាជាក់ស្ដែងទាក់ទងទៅនឹងភាពអាចទទួលយកបាននៃបណ្ដឹង សាទុក្ខទាំងនេះ កសព គួរតែបានធ្វើការឆ្លើយតបទៅនឹងទឡ្ហីករណ៍នៃភាពអាចទទួលយកបាន ដែលបានលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខនៅពេលដែលបណ្ដឹងទុក្ខទាំងនេះត្រូវបានដាក់។ ផ្ទុយទៅ វិញ កសព បែរជាលើកឡើងដោយមិនបានសូម្បីតែឃើញបណ្ដឹងសាទុក្ខផងថាបណ្ដឹងសាទុក្ខ ទាំងនេះ "គ្មានមូលដ្ឋានជាក់ស្ដែងច្បាស់ក្រឡែត" ហើយថាមេធាវីការពារក្ដីមិនត្រូវបានអនុញ្ញាតឱ្យ ដាក់សូម្បីតែបណ្ដឹងសាទុក្ខទាំងនេះ ឬការឆ្លើយតបទៅនឹងចម្លើយតបរបស់ខ្លួនផងទេ[17] ។ មិនដឹង ថាវានឹងមានភាពងាយស្រួលចំពោះ កសព ប៉ុណ្ណោះទេ ប្រសិនបើមេធាវីការពារក្ដីមិនត្រូវបាន អនុញ្ញាតឱ្យដាក់បណ្ដឹងសាទុក្ខ ដោយគ្រាន់តែផ្អែកលើការអះអាងរបស់ កសព ដែលថាបណ្ដឹង សារទុក្ខរបស់មេធាវីការពារក្ដីគ្មានមូលដ្ឋានជាក់ស្ដែង ហើយប្រសិនបើ កសព មិនចាំបាច់លំបាក ដល់ខ្លួនក្នុងការពិចារណាអំពីទឡ្ហីករណ៍ជាក់ស្ដែងរបស់មេធាវីការពារក្ដី។

## II. សំណូមពរ

**ដូច្នេះ** អាស្រ័យលើមូលហេតុដែលបានលើកឡើងក្នុងចម្លើយតបនេះ មេធាវីការពារក្ដីសូមស្នើឱ្យអង្គជំនុំ ជម្រះតុលាការកំពូល**បដិសេធចោល** ចម្លើយតបរបស់ កសព ហើយទទួលយកការដាក់បណ្ដឹងសាទុក្ខ។

---

[16] សូមមើលសេចក្ដីណែនាំអនុវត្តន៍ស្ដីពីការដាក់ឯកសារនៅ អវតក, សេចក្ដីណែនាំអនុវត្តន៍នៅ អវតក/០១/២០០៧/ វិសោធនកម្មលើកទី៦, មាត្រា៨.៣។

[17] តាមរយៈការជូនដំណឹងទាំងពីរនេះ កសព "ស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលចេញដីកាហាមឃាត់មិនឱ្យមេធាវីការពារក្ដី ដាក់សារណាបណ្ដឹងសាទុក្ខបន្ថែមទៀតឡើយដោយផ្អែលើមូលដ្ឋានដែលថាបណ្ដឹងសាទុក្ខ គ្មានមូលដ្ឋានជាក់ស្ដែងច្បាស់ក្រឡែត នឹងអាចនាំឱ្យមានការខ្ជះខ្ជាយធនធានរបស់ អគវក ភាគី និងអង្គជំនុំជម្រះតុលាការកំពូល"។ ចម្លើយតប កថាខណ្ឌទី១។

សូមចៅក្រមអង្គជំនុំជម្រះតុលាការកំពូលទទួលយកការឆ្លើយតបនេះដោយក្តីគោរព ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី